# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:....៩២....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតំឡើងការិយាល័យអាស៊ាន និងអង្គការពាណិជ្ជកម្ម ពិភពលោក ( WTO ) ទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

~~~~~~~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសម្រួល និង បំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០៣ ស្តីពីការតំឡើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាលទៅជា អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
~~~~~~~

## ស ម្រេ ច

**មាត្រា១:** ត្រូវបានតំឡើងការិយាល័យអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក ( WTO ) នៃនាយកដ្ឋានទូរគមនាគមន៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**មាត្រា២:** នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ÷

- រៀបចំលើកគម្រោងសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ ដែលពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ តាមគោលការណ៍របស់រាជរដ្ឋាភិបាល ។
- រៀបចំសំណុំលិខិតផ្សេងៗ ដែលពាក់ព័ន្ធនឹងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ចរចា និងចុះហត្ថលេខា លើកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀង ។
- ប្រមូលផ្តុំមតិយោបល់លើសន្ធិសញ្ញាអន្តរជាតិ ដែលតម្រូវឱ្យក្រសួងចូលរួមមតិ ។
- តាមដានការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានចែងក្នុងកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ។
- តាមដាន និងស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងសហភាពប្រៃសណីយ៍សកល ( UPU ) សហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិច ( APPU ) សហភាពទូរគមនាគមន៍អន្តរជាតិ ( ITU ) ទូរគមនាគមន៍អាស៊ីប៉ាស៊ីហ្វិច ( APT ) ។
- ចូលរួមការងារដែលទាក់ទងនឹងមហាអនុតំបន់ទន្លេមេគង្គ ( GMS ) ។
- សហការ និងសម្របសម្រួលជាមួយនាយកដ្ឋានជំនាញក្នុងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងលេខាធិការដ្ឋានអាស៊ាន លើការងារសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន ។
- លើកគម្រោងចំណាយប្រចាំឆ្នាំសម្រាប់ដំណើរការកិច្ចសហប្រតិបត្តិការអន្តរជាតិនិងកិច្ចការអាស៊ាន
- រៀបចំកិច្ចប្រជុំ និងឯកសារ សម្រាប់កិច្ចប្រជុំពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន ។
- បូកសរុបលទ្ធផលការងារសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន ។

**មាត្រា៣:** នាយកដ្ឋាននេះ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា៤:** រចនាសម្ព័ន្ធ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលមានការិយាល័យមួយចំនួនចំណុះ និង ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន និងការិយាល័យ ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា៥:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់គ្រងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៥*

ហ៊ុន សែន

**បានយកសេចក្តីជម្រាបជូន**

សម្តេចនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សូ ឃុន

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ-កាលប្បវត្តិ*